

Helping your child with literacy and numeracy at home

Khmer

# ការជួយកូនរបស់អ្នក ជាមួយចំណេះដឹង ផ្នែកអក្ខរកម្ម និងលេខនព្វន្តនៅផ្ទះ

ក្រសួងអប់រំ រដ្ឋ NSW

កូនសៀវភៅនេះបានបង្កើតឡើងសម្រាប់ឪពុកម្តាយ អ្នកថែទាំ និងក្រុមគ្រួសារកុមារក្នុងឆ្នាំដំបូងនៃការរៀនសូត្រនៅសាលារៀន។

កូនសៀវភៅនេះមានពេញទៅដោយសកម្មភាពដើម្បីគាំទ្រដល់ការរៀនសូត្រសំខាន់ដែលកើតមានឡើងនៅផ្ទះ។ សកម្មភាពទាំងនេះត្រូវបានរចនាឡើង ដើម្បីឱ្យអ្នកមានភាពសប្បាយរីករាយជាមួយកូនរបស់អ្នក និងជួយពួកគេឱ្យបានចាប់ផ្តើមយ៉ាងល្អនៅសាលារៀន។

ចូរលើកទឹកចិត្តឱ្យកូនរបស់អ្នកចូលរួម និងរុករកសកម្មភាពទាំងនេះ ហើយគាំទ្រដល់ការឆ្លើយតបរបស់ពួកគេម្នាក់ៗ។

# មាតិកា


## អក្ខរកម្ម 4

ការនិយាយ និងការស្តាប់ 5

ការអាន 10

ការគូរ និងការសរសេរ 16

## លេខនព្វន្ត 21

លេខ និងការរាប់លេខ 22

ការបូក និងការដក 28

ការកំណត់អត្តសញ្ញាណ និងការបង្កើតលំនាំ 32

# អក្ខរកម្ម

## ការជួយកូនរបស់អ្នកឱ្យអភិវឌ្ឍជំនាញអក្ខរកម្មរបស់ពួកគេ

**អក្ខរកម្មទាក់ទិននឹងការស្តាប់ ការនិយាយ ការអាន ការសរសេរ និងការប្រកប។ វាជាសមត្ថភាពដើម្បីប្រាស្រ័យទាក់ទងការត្រិះគិត និងអារម្មណ៍ គំនិត និងយោបល់ ហើយបង្កើតអត្ថន័យចេញពីសារដែលនិយាយ និងសរសេរ។**



# ការនិយាយ និងការស្តាប់

ជំនាញក្នុងការនិយាយ និងការស្តាប់ បង្កើតគ្រឹះសម្រាប់ការរៀនសូត្ររបស់កូនអ្នកនៅសាលារៀន។ ជំនាញទាំងនេះជួយឱ្យកុមារអាចនិយាយជាមួយអ្នកដទៃ បង្កើតមិត្តភាព និងចូលរួមយ៉ាងសកម្មក្នុងគ្រប់សកម្មភាពទាំងអស់នៅសាលារៀន។

ប្រសិនបើអ្នកនិយាយភាសាផ្សេងក្រៅពីភាសាអង់គ្លេសនៅផ្ទះ វាជាការសំខាន់ដែលអ្នកត្រូវបន្តគាំទ្រកូនរបស់អ្នក ឱ្យប្រើប្រាស់ភាសាកំណើតរបស់ពួកគេ។

# ការនិយាយជាមួយកូនរបស់អ្នក

- **និយាយជាមួយកូនរបស់អ្នក**អំពីប្រធានបទជាច្រើន ឧទាហរណ៍ អំពីអ្វីៗដែលកើតឡើងរៀងរាល់ថ្ងៃ។
- **ចែករំលែករឿងហេតុ**ពីវប្បធម៌របស់អ្នក រឿងផ្ទាល់ខ្លួន និងរឿងរបស់កូនអ្នក។
- **ពិពណ៌នា ឬនិយាយអំពីរឿងហេតុ**ដែលកំពុងកើតឡើង។ ឧទាហរណ៍៖ "យើងនឹងនំាគ្នាដើរទៅសាលារៀនថ្ងៃនេះ ហើយដើរកាត់សួននេះ។"
- **ស្តាប់កូនរបស់អ្នក និងលើកទឹកចិត្តពួកគេឱ្យឆ្លាស់វេនគ្នា។** បង្ហាញពីរបៀបស្តាប់ និងប្រាស្រ័យទាក់ទងគ្នាក្នុងការសន្ទនា។
- នៅពេលចាប់ផ្តើមការសន្ទនា ឬនៅពេលនិយាយជាមួយកូនរបស់អ្នក **សួរសំណួរ**ដែលតម្រូវច្រើនជាងត្រឹមតែការឆ្លើយថាបាទ/ចាស៎ ឬមិនឆ្លើយតប។ ឧទាហរណ៍ "តើកូនបានធ្វើអ្វីខ្លះនៅសាលារៀនថ្ងៃនេះ?"
- ប្រើសំណួរដែល**ចាប់ផ្តើមជាមួយបែបណា ឬហេតុអ្វី**។ ឧទាហរណ៍ "តើកូនឃើញសត្វស្លាបប៉ុន្មាននៅក្នុងសួន?"
- នៅពេលសួរសំណួរ **ចូរផ្តល់ពេលវេលាដើម្បីឱ្យកូនរបស់អ្នកឆ្លើយ។**
- **ធ្វើឱ្យការសន្ទនាមានភាពសប្បាយរីករាយ**។ បង្កើតរឿងកំប្លែង និយាយ និងច្រៀងជាមួយកូនរបស់អ្នក។

# ការប្រាស្រ័យទាក់ទងនឹងសារ

- **និទានរឿងឡើងវិញ**។ និយាយអំពីអ្វីដែលបានកើតឡើងនៅដើមដំបូង ពាក់កណ្តាល និងចុងបញ្ចប់នៃរឿង។
- បន្ទាប់ពីអានរួច **និយាយអំពីតួអង្គ** ឬផ្នែកនៃសៀវភៅដែលកូនរបស់អ្នកចូលចិត្ត។
- **ចែករំលែកគំនិត**អំពីអ្វីដែលអាចនឹងកើតឡើង នៅពេលទៅកន្លែងព្រឹត្តិការណ៍ណាមួយដូចជាការធ្វើពិធីអបអរ ឬការទៅសាលារៀន។ បន្ទាប់ពីព្រឹត្តិការណ៍ និយាយអំពីអ្វីដែលបានកើតឡើង ហើយសុំឱ្យពួកគេចែករំលែកគំនិត និងអារម្មណ៍របស់ពួកគេ។
- គាំទ្រកូនរបស់អ្នកឱ្យ**បង្កើតរឿងផ្ទាល់ខ្លួនរបស់ពួកគេចេញ**ពីការស្រមើស្រមៃរបស់ពួកគេ។ សួរសំណួរដូចជា "តើរឿងនេះគឺអំពីអ្វី?" "តើនរណានៅក្នុងរឿងនេះ?" "តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ?"
- **បង្រៀនកូនរបស់អ្នកអំពីឈ្មោះរបស់ពួកគេ** អាសយដ្ឋាន អាយុ ថ្ងៃខែឆ្នាំកំណើត និងលេខទូរស័ព្ទ។
- បន្ទាប់ពីសាលារៀន សួរកូនរបស់អ្នកថាតើការរៀនសូត្ររបស់ពួកគេនៅថ្ងៃនេះយ៉ាងម៉េចដែរ ហើយ**សួរព័ត៌មានបន្ថែម** ឧទាហរណ៍ "ហេតុអ្វីបានជាកូនមានអារម្មណ៍យ៉ាងនេះ?"



# សៀវភៅដើម្បីជួយកូនអ្នកជាមួយជំនាញការសន្ទនា ជាភាសាអង់គ្លេស និងការបង្កើតពាក្យ


















# ការបង្កើតពាក្យ

- **ប្រើពាក្យពិពណ៌នា** នៅពេលនិយាយ។
ប្រសិនបើកូនរបស់អ្នកនិយាយថា "មានឆ្កែមួយ"។ ចូរបន្ថែមការពិពណ៌នាដូចជា "ឆ្កែនោះតូច មានរោមត្រសុសពណ៌ស។"
- សាងសង់លើភាសារបស់កូនអ្នក ដោយ**បង្រៀនពួកឱ្យចេះពាក្យថ្មីៗ**។
- នៅពេលអានជាមួយកូនរបស់អ្នក **និយាយអំពីពាក្យ**ដែលប្រើនៅក្នុងសៀវភៅ។ ពិភាក្សាជាមួយគ្នាអំពីអត្ថន័យនៃពាក្យ។ អ្នកក៏ប្រហែលជាចង់ស្វែងរកពាក្យថ្មីៗ និងគួរឱ្យចាប់អារម្មណ៍ដើម្បីនិយាយផងដែរ។
- **ហាត់**ប្រើពាក្យថ្មីៗនៅក្នុងប្រយោគ។
- **ធ្វើស្លាក**សម្រាប់វត្ថុនៅជុំវិញផ្ទះ។



# ការអាន

កុមាររៀនចេះពេលណាមានគេអានឱ្យពួកគេស្តាប់ ការអានជាមួយអ្នកដទៃ និងការអានដោយខ្លួនឯង។

សប្បាយរីករាយក្នុងការអានជាមួយគ្នាឱ្យបានរាល់ថ្ងៃ។ ស្វែងរកឱកាសទាំងឡាយដូចជាពេលអ្នកកំពុងដើរទៅសាលារៀន ហាងលក់សៀវភៅ បណ្ណាល័យ និងផ្សារទំនើប។

និយាយអំពីរឿង ភាសាដែលបានប្រើពាក្យនៅក្នុងរឿង ក៏ដូចជាសម្លេងនៃអក្សរនៅក្នុងពាក្យ។ អានសៀវភៅជាភាសាកំណើតរបស់អ្នក។

# អានជាមួយកូនរបស់អ្នកឱ្យបានរាល់ថ្ងៃ

- **ធ្វើឱ្យការអានអរសប្បាយ** និងជាទីរីករាយ។ កុមាររៀនចេះអំពីការអានដោយការមើល ការចម្លងតាម និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។
- **ឱ្យកូនរបស់អ្នកជ្រើសរើស និងអានសៀវភៅឡើងវិញ** ដែលពួកគេចាប់អារម្មណ៍។
- **និយាយអំពីសៀវភៅ** មុនពេលអ្នកចាប់ផ្ដើមអាន។ និយាយពីចំណងជើង និងអ្វីដែលអាចកើតឡើងនៅក្នុងរឿង។
- **ពិភាក្សាអំពីរូបភាព** និងវិធីដែលវារួមចំណែកទៅក្នុងរឿង។
- ខណៈពេលកំពុងអាន **សួរសំណួរទៅកូនរបស់អ្នក**អំពីរឿងដូចជា "តើកូនគិតថាអាចនឹងមានអ្វីកើតឡើងបន្ទាប់ទៀត?" "ហេតុអ្វីបានជាកូនគិតដូច្នេះ?"
- បន្ទាប់ពីអាន **ចូរនិយាយអំពីរឿង**។ សួរសំណួរដូចជា "តើផ្នែកមួយណានៃរឿងនេះដែលកូនចូលចិត្តជាងគេ?" ឬ "តើអ្វីដែលគួរឱ្យរំភើប គួរឱ្យអស់សំណើច ឬកំសត់នៅក្នុងរឿងនេះ?"
- **ឆ្លាស់វេនគ្នានៅពេលអាន**រឿងដែលចូលចិត្តជាមួយកូនរបស់អ្នក និងបងប្អូនប្រុសស្រី ឬមិត្តភក្តិ។
- **ជ្រើសរើសសម្ភារៈអានផ្សេងៗគ្នា**ដូចជាសារព័ត៌មាន ទស្សនាវដ្ដី ផ្ទាំងរូបភាព សញ្ញាផ្លូវ រូបមន្តធ្វើម្ហូប និងបញ្ជីទិញឥវ៉ាន់។

# សៀវភៅភាសាអង់គ្លេសដែលមានពាក្យចួន















# មានភាពសប្បាយរីករាយជាមួយនឹង ការអាន ភាសា និងពាក្យ

- **ជ្រើសរើសសៀវភៅភាសាអង់គ្លេសដែលមានពាក្យចួន** ឬពាក្យប្រដៅនៅក្នុងនោះ។
- **និយាយអំពីពាក្យចួនគ្នា**។ Cat, hat, sat, bat គឺជាឧទាហរណ៍នៃពាក្យដែលចួនគ្នាក្នុងភាសាអង់គ្លេស ពីព្រោះវាមានសម្លេងដូចគ្នានៅចុងពាក្យ។
- **លេងជាមួយពាក្យចួនគ្នា** និងលេងល្បែងពាក្យចួនគ្នាជាភាសាអង់គ្លេស។ បង្កើតឃ្លាដែលមានពាក្យចួនគ្នាដូចជា “Have you ever seen a snail deliver the mail?”











# លេងជាមួយសម្លេងអក្សរ

- **សប្បាយរីករាយជាមួយសម្លេងអក្សរ។** បង្កើតប្រយោគដែលកំប្លុកកំប្លែង ដោយប្រើពាក្យដែលចាប់ផ្តើមជាមួយសម្លេងដូចគ្នា។
- នៅពេលអ្នកអានឱ្យកូនរបស់អ្នកស្តាប់ ប្រាប់ឱ្យពួកគេចង្អុល **និងនិយាយសម្លេង**ដែលពួកគេស្គាល់។
- **លេងល្បែងសម្លេង**ដែលមានឈ្មោះកូនរបស់អ្នក។ សួរសំណួរដូចជា "តើឈ្មោះកូនចាប់ផ្តើមជាមួយសម្លេងអ្វី?" "តើវាមានសម្លេងដូចគ្នានឹងសម្លេងនៅដើមពាក្យ dad ទេ?"

# សៀវភៅអំពីអក្សរជាភាសាអង់គ្លេស














# ការអាន និងការសរសេរ

លើកទឹកចិត្តឱ្យកូនរបស់អ្នកគូរ និងសរសេរអំពីអ្វីដែលគួរឱ្យចាប់អារម្មណ៍។

ប្រាប់ឱ្យកូនរបស់អ្នកនិយាយអំពីគំនូរ និងការសរសេររបស់ពួកគេ។ ឱ្យមានការចាប់អារម្មណ៍លើរឿងរបស់ពួកគេ និងវិធីដែលពួកគេបានជ្រើសរើសគូរ ឬសរសេរ។



# សរសេរឱ្យបានរាល់ថ្ងៃ

- **សប្បាយរីករាយជាមួយនឹងការគូរ និងការសរសេរ។** ប្រាប់ឱ្យកូនរបស់អ្នកគូរ ឬសរសេរអំពីអ្វីដែលពួកគេចូលចិត្តធ្វើ បង្កើត ឬលេង។
- **លើកទឹកចិត្តឱ្យកូនរបស់អ្នកនិយាយអំពីការសរសេររបស់ពួកគេ។** នេះអាចរួមមានការនិយាយអំពីការគូសវាស គំនូរ អក្សរ ឬពាក្យរបស់ពួកគេ។
- **ប្រើសម្ភារផ្សេងៗគ្នា**ដូចជាដីស ក្រដាស និងខ្មៅដៃ ប៊ិចគូសចំណាំ និងប៊ិចដើម្បីគូរ និងសរសេរជាមួយ។
- ប្រាប់ឱ្យកូនរបស់អ្នក**សរសេរឈ្មោះរបស់ពួកគេ**។ កូនរបស់អ្នកក៏អាចព្យាយាមសរសេរឈ្មោះមនុស្សផ្សេងទៀត ដែលមានសារៈសំខាន់ចំពោះពួកគេដែរ។
- ខណៈពេលដែលកូនរបស់អ្នកកំពុងសរសេរ ឬគូរ **ចូរនិយាយអំពីរូបភាព និងសម្លេង**នៃអក្សរដែលកូនរបស់អ្នកកំពុងព្យាយាមសរសេរ។
- **លើកទឹកចិត្តឱ្យកូនរបស់អ្នកប្រើការស្រមើលស្រមៃរបស់ពួកគេ** និងបង្កើតរឿង។ ពួកគេអាចបង្កើតសៀវភៅរឿងមួយ ដោយគូររូបភាព និងសរសេរពាក្យសម្រាប់រឿងនោះ។
- គាំទ្រកូនរបស់អ្នកឱ្យ**សរសេរសារជាភាសាកំណើតរបស់ពួកគេ**។



## ការគូរ និងការសរសេរសម្រាប់គោលបំណងអ្វីមួយ

- **លើកទឹកចិត្តឱ្យកូនរបស់អ្នកគូរ ឬសរសេរ** បញ្ជីទិញឥវ៉ាន់។ ឬអំពីមនុស្សដែលពួកគេចូលចិត្តនៅក្នុងគ្រួសារ ឬសៀវភៅដែលពួកគេចូលចិត្ត។
- **បង្កើតបទចំរៀង ឬកំណាព្យ** ហើយសរសេរពាក្យ ឬគូររូបភាពរូបដើម្បីភ្ជាប់ទៅនឹងចម្រៀង ឬកំណាព្យនោះ។
- **សួរកូនរបស់អ្នកឱ្យរៀបរាប់**អំពីអ្វីដែលពួកគេកំពុងគូរ ឬសរសេរពេលដែលពួកគេកំពុងបង្កើត។
- លើកទឹកចិត្តឱ្យពួកគេ**សរសេរសំបុត្រ**ទៅមិត្តភក្តិ ឬនរណាម្នាក់នៅក្នុងគ្រួសារ អំពីអ្វីដែលគួរឱ្យចាប់អារម្មណ៍ គួរឱ្យអស់សំណើច ឬគួរឱ្យរំភើបដែលបានកើតឡើង។
- **ឱ្យមានកូនសៀវភៅ ឬសៀវភៅកំណត់ហេតុប្រចាំថ្ងៃ** ដែលកូនរបស់អ្នកអាចសរសេរ ឬគូរជារៀងរាល់ថ្ងៃ។
- **បង្កើតប័ណ្ណ** ឬការអញ្ជើញសម្រាប់ការធ្វើពិធីអបអរ ឬព្រឹត្តិការណ៍ពិសេស។



# និយាយអំពីសារ

- ប្រាប់កូនរបស់អ្នក**ឱ្យបង្កើតសារ**ដែលពួកគេចង់ផ្ញើ។ វាអាចជាផ្ទាំងរូបភាព ដូចជា "ប្រយ័ត្នឆ្កែខាំ" ឬសំបុត្រទៅគ្រូរបស់ពួកគេអំពីអ្វីដែលពួកគេចូលចិត្តធ្វើ។
- **ប្រើពាក្យប្រចាំថ្ងៃ**ដែលជាផ្នែកនៃវប្បធម៌ បទពិសោធន៍ និងចំណាប់អារម្មណ៍របស់កូនអ្នក។
- **និយាយអំពីរឿង ឬអក្សរ**ដែលកូនអ្នកបានសរសេរ ឬដែលអ្នកបានអានជាមួយគ្នា។
- នៅពេលនិយាយ ចូរគាំទ្រកូនរបស់អ្នកឱ្យ**និយាយជាប្រយោគដោយប្រើពាក្យផ្សេងៗគ្នា**។







# លេខនព្វន្ត

## ជួយកូនរបស់អ្នកឱ្យអភិវឌ្ឍជំនាញលេខនព្វន្តរបស់ពួកគេ

លេខនព្វន្តទាក់ទងនឹងការអាចយល់ដឹងពីរបៀបដែលលេខដំណើរការក្នុងស្ថានភាពប្រចាំថ្ងៃ។

យើងឃើញ និងប្រើលេខរៀងរាល់ថ្ងៃ។ នៅពេលអាន នោះមានលេខនៅលើទំព័រ ផ្ទះរបស់យើងមានលេខ ហើយពេលយើងទិញអ្វីមួយយើងបូក និងដកលេខ។

ជួយកូនអ្នកឱ្យបង្កើតអាកប្បកិរិយាវិជ្ជមាន ឆ្ពោះទៅរកលេខនព្វន្ត។

វាមានសារសំខាន់ក្នុងបង្កើតជំនាញ លេខនព្វន្តជាភាសាកំណើតរបស់អ្នក។



# លេខ និងការរាប់លេខ

ជំនាញដំបូងដែលកុមារកំពុងអភិវឌ្ឍ គឺការរាប់។ ការរាប់ រួមមាន៖

- ការនិយាយ និងការរំលឹកលេខតាមលំដាប់លំដោយត្រឹមត្រូវ
- ការផ្គូផ្គងពាក្យលេខទៅនឹងវត្ថុ
- ការដឹងថាលេខចុងក្រោយដែលបានរាប់ តំណាងឱ្យចំនួនវត្ថុសរុប។

## ពាក្យដែលត្រូវប្រើ

- រាប់ទៅមុខ រាប់ថយក្រោយ
- លេខមុន លេខបន្ទាប់
- ច្រើនជាង តិចជាង
- គឺដូចគ្នានឹង។

# លេខជាភាសាអង់គ្លេស

| | | | |
|---|---|---|---|
| 0 | zero | 1 | one |
| 2 | two | 3 | three |
| 4 | four | 5 | five |
| 6 | six | 7 | seven |
| 8 | eight | 9 | nine |
| 10 | ten | | |




# សកម្មភាពដើម្បីលើកទឹកចិត្តឱ្យរៀនអំពីលេខ

- **ប្រើកូនឡុកឡាក់ដែលមានលេខ និងចំណុច** ដើម្បីជួយកូនរបស់អ្នកឱ្យស្គាល់ចំណាំលេខ និងបរិមាណ។ សួរកូនរបស់អ្នកថា "តើមានចំណុចប៉ុន្មាននៅលើកូនឡុកឡាក់នេះ?"
- **លេងល្បែងលើក្តារជាមួយគ្នា**ដែលប្រើកូនឡុកឡាក់ និងការរាប់។
- **អាន និងចែករំលែករឿង**។ និយាយអំពីការរាប់ ចំនួន និងលេខដែលអ្នកឃើញនៅក្នុងសៀវភៅ រួមទាំងលេខទំព័រ។
- **សួរឱ្យកូនរបស់អ្នកស្វែងរកលេខនៅពេលចេញទៅដើរលេង**។ សួរកូនរបស់អ្នកថា "តើកូនអាចឃើញមានលេខអ្វីខ្លះ?" និយាយអំពីលេខផ្ទះ ស្លាកលេខរថយន្ត និងស្លាកសញ្ញាផ្លូវ។
- **និយាយអំពីលេខ**នៅលើវត្ថុប្រើប្រាស់ប្រចាំថ្ងៃដូចជានាឡិកា និងទូរស័ព្ទ។ ជួយកូនរបស់អ្នកឱ្យរំលឹកឡើញវិញនូវលេខដែលមានប្រយោជន៍។

# ការទទួលស្គាល់ចំនួនវត្ថុ ឬចំណុច

## លំនាំចំណុចកូនឡុកឡាក់



## លំនាំចំណុច




## លំនាំចំណុចដូមីណូ (Domino)



# ការរាប់ជាមួយកូនរបស់អ្នក

- **រាប់នៅពេលអ្នកធ្វើអ្វីៗជុំវិញផ្ទះ**។ ចំអិនអាហារដែលមានរូបមន្តងាយៗជាមួយគ្នា ហើយឱ្យកូនរបស់អ្នករាប់ពីគ្រឿងផ្សំ។
- **លើកទឹកចិត្តកូនរបស់អ្នកឱ្យជួយរៀបចំតុ**សម្រាប់អាហារគ្រួសារ។ សួរឱ្យពួកគេរាប់ចំនួនមនុស្ស និងចាន ពែង សម និងស្លាបព្រាដែលត្រូវការសម្រាប់តុ។
- **រាប់ជាមួយកូនរបស់អ្នក**ពីចំនួនឡេវអាវ នៅពេលពួកគេពាក់អាវសាលា។
- សួរឱ្យកូនរបស់អ្នក**រាប់ចំនួនវត្ថុ**ដែលមាននៅក្នុងប្រអប់អាហារថ្ងៃត្រង់របស់ពួកគេ។
- **រាប់ទៅមុខ**។ រាប់វត្ថុប្រើប្រាស់ប្រចាំថ្ងៃដូចជាឡាន ផ្ទះ ស្បែកជើង និងកាបូប។
- **រាប់ថយក្រោយ**។ ការចុះជណ្តើរ បន្ទាប់មកឡើងជណ្តើរ។ 10, 9, 8 ....

## ចម្រៀងរាប់ជាភាសាអង់គ្លេស



- Here is the Beehive
- Five Little Ducks
- The Ants Go Marching
- One, Two, Buckle My Shoe
- Five Cheeky Monkeys Jumping on the Bed
- Ten Green Bottles

# សៀវភៅអំពីលេខ
# និងការរាប់ជាភាសាអង់គ្លេស

















# ការបូក និងការដក

កុមារតូចៗចាំបាច់ត្រូវបង្កើតអារម្មណ៍នៃការដឹងអំពីការបូក និងការដក។ នេះរួមមានការដាក់បញ្ចូលគ្នានូវវត្ថុពីរ ឬច្រើន និងការដក និងការបំបែកវត្ថុ។

## ពាក្យដែលត្រូវប្រើ

- រួមផ្សំជាមួយ ភ្ជាប់ ធ្វើ
- តិចជាង ច្រើនជាង
- ទាំងអស់គ្នា
- ដកចេញ
- ប៉ុន្មានទៀត

# សកម្មភាពដែលជួយលើកទឹកចិត្តដល់ការបូក

- **បូកចំនួនវត្ថុប្រើប្រាស់ប្រចាំថ្ងៃ** ប្រដាប់ក្មេងលេង ផ្លែឈើ សៀវភៅ។ កុមារអាចប្រើម្រាមដៃរបស់ពួកគេដើម្បីបូក។
- នៅពេលអ្នកកំពុងដើរ **បូកចំនួនវត្ថុផ្សេងៗគ្នា**ដែលអ្នកមើលឃើញ ឧទាហរណ៍ ផ្កានៅក្នុងសួនច្បារ។
- នៅលើប្រតិទិន ប្រាប់ឱ្យកូនរបស់អ្នកគូសសម្គាល់ថ្ងៃដែលពួកគេទៅសាលារៀន ឬធ្វើសកម្មភាពមួយផ្សេងទៀត។ នៅចុងសប្ដាហ៍ **បូកចំនួនថ្ងៃសម្រាប់សកម្មភាពនីមួយៗ**។
- នៅពេលអ្នកទិញឥវ៉ាន់ ចូរនិយាយអំពីអ្វីដែលអ្នកត្រូវការទិញ។ **សួរសំណួរ**ដូចជា "តើត្រូវការចេកប៉ុន្មានសម្រាប់មនុស្សគ្រប់គ្នាក្នុងគ្រួសារ? ប្រសិនបើខ្ញុំទទួលបានមួយបន្ថែមទៀត តើយើងនឹងមានប៉ុន្មាន?"។
- **លេងល្បែងដែលជួយលើកទឹកចិត្តដល់ការបូកដោយប្រើកូនឡុកឡាក់ពីរ** ឧទាហរណ៍ "Snakes and Ladders"។





# សកម្មភាពដើម្បីជួយលើកទឹកចិត្តដល់ការដក

- **ដកវត្ថុប្រើប្រាស់ប្រចាំថ្ងៃ។** រាប់វត្ថុដែលមាននៅក្នុងប្រអប់អាហារថ្ងៃត្រង់របស់ពួកគេ ហើយបន្ទាប់មក ដកនៅពេលយកវត្ថុចេញពីប្រអប់។
- **នៅពេលញ៉ាំអាហារ រាប់ចំនួនវត្ថុ**ដែលអ្នកមាន។ សួរសំណួរដូចជា "តើកូនបានញ៉ាំផ្លែទំពាំងបាយជូរអស់ប៉ុន្មាន ហើយតើនៅសល់ប៉ុន្មានទៀត?"
- **លើកទឹកចិត្តកូនរបស់អ្នកឱ្យកត់សម្គាល់ពីភាពខុសគ្នានៅពេលយកវត្ថុចេញ** ដូចជាយកស៊ុតចេញពីប្រអប់កាតុង ឬយកចេកចេញពីស្និត។
- **ច្រៀងចម្រៀង**ដូចជា "Five Little Ducks" ដែលកាត់បន្ថយចំនួនវត្ថុ ខណៈពេលវត្ថុមួយត្រូវបានយកចេញ។
- **សួរសំណួរ**ដូចជា "យើងមានផ្លែប៉ោមប្រាំនៅក្នុងចាន។ ប្រសិនបើខ្ញុំញ៉ាំអស់ផ្លែប៉ោមពីរ តើនៅសល់ផ្លែប៉ោមប៉ុន្មាន?"

# សៀវភៅអំពីការបូក
# និងការដកជាភាសាអង់គ្លេស














# ការកំណត់អត្តសញ្ញាណ និងការបង្កើតលំនាំ

**លំនាំគឺជាសំណុំដដែលៗ។ វាអាចធ្វើចេញពីរូបរាង សម្លេង លេខ ឬវត្ថុ។**

**កុមារអាចរៀនសម្គាល់ដឹង កំណត់អត្តសញ្ញាណ បង្កើត ចម្លងតាម និងបន្តលំនាំតាមរយៈសកម្មភាពប្រចាំថ្ងៃ។**





## ពាក្យដែលត្រូវប្រើ

- ធ្វើម្តងទៀត
- បន្ត
- បង្កើត
- កំណត់អត្តសញ្ញាណ
- ពិពណ៌នា
- លំនាំ
- ដូចគ្នា
- ខុសគ្នា

## សម្គាល់ដឹង និងកំណត់អត្តសញ្ញាណលំនាំ

- **កំណត់អត្តសញ្ញាណលំនាំ** ដូចជានៅលើក្រដាសរុំឥដ្ឋក្រាលនៅបន្ទប់ទឹក និងច្រកឡានបើកចូលផ្ទះ។ និយាយអំពីលំនាំផ្សេងៗគ្នា និងអ្វីដែលបង្កើតជាលំនាំ។
- **និយាយអំពីលំនាំ។** សួរសំណួរដូចជា "ហេតុអ្វីវាជាលំនាំ?" " តើកូនអាចបន្តលំនាំនេះបានទេ?"
- **លេងល្បែងដោយប្រើកាតដូមីណូ** (domino) **ឬកូនឡុកឡាក់**ដើម្បីជួយកូនរបស់អ្នកឱ្យសម្គាល់ដឹងពីលំនាំ។

# ការចម្លងតាមលំនាំ

- លេងល្បែងទះដៃដែលអ្នក**ទះដៃជាលំនាំ** ហើយឱ្យកូនរបស់អ្នកធ្វើតាមលំនាំនោះម្តងទៀត។ សួរឱ្យកូនរបស់អ្នកទះដៃតាមលំនាំដែលអ្នកធ្វើម្តងទៀត។
- **រៀបតុជាមួយគ្នាសម្រាប់អាហារដោយប្រើលំនាំ** ដូចជាចាននិងស្លាបព្រា ចាននិងស្លាបព្រា ចាននិងស្លាបព្រា។

# ការបង្កើតលំនាំ

- **បង្កើតលំនាំជាមួយវត្ថុប្រើប្រាស់ប្រចាំថ្ងៃ** ដូចជាប្រដាប់ប្រដាក្មេងលេង និងផ្លែឈើ។
- **ចាប់ផ្តើមជាមួយលំនាំសាមញ្ញ** ហើយបន្ទាប់មក **បង្កើតលំនាំកាន់តែពិបាក** ដូចជាផ្លែប៉ោមមួយ ផ្លែចេកពីរ ផ្លែប៉ោមមួយ ផ្លែចេកពីរ ផ្លែប៉ោមមួយ ផ្លែចេកពីរ។



# សៀវភៅអំពីលំនាំជាភាសាអង់គ្លេស















# សៀវភៅដើម្បីជួយកូនរបស់អ្នកអភិវឌ្ឍជំនាញអក្ខរកម្មភាសាអង់គ្លេស

## សៀវភៅសម្រាប់ការសន្ទនា និងការបង្កើតពាក្យ

**Dunbi the Owl** – Daisy Utemorrah, editor Pamela Lofts. Scholastic Australia

**Possum Magic** – Mem Fox, illustrator Julie Vivas. Omnibus Books

**Splosh for the Billabong** – Ros Moriarty, illustrator Balarinji. Allen and Unwin

**The Day the Crayons Quit** – Drew Daywalt, illustrator Oliver Jeffers. Harper Collins Children's Books

**The Echidna and the Shade Tree** – Mona Green, editor Pamela Lofts. Scholastic Australia

**The Little Refugee** – Anh and Suzanne Do, illustrator Bruce Whatley. Allen & Unwin Children

**The True Story of the 3 Little Pigs** – Jon Scieszka, illustrator Lane Smith. Penguin

**The Very Cranky Bear** – Nick Bland. Scholastic Australia

## សៀវភៅដែលមានពាក្យចួនគ្នា

**Miss Spider’s Tea Party** – David Kirk. Scholastic Inc

**No Way Yirrikipayi!** – Alison Lester. Pan Macmillan Australia

**Pig the Pug** – Aaron Blabey. Scholastic Australia

**Piranhas Don’t Eat Bananas** – Aaron Blabey. Scholastic Australia

**Oi Cat!** – Kes Gray, Jim Field. Hachette Australia

**Sebastian Lives in a Hat** – Thelma Catterwell, illustrator Kerry Argent. Omnibus Books

**Walking Through the Jungle** – Stella Blackstone. Barefoot Books

**The Cat in the Hat** – Dr Seuss. Random House

## សៀវភៅអំពីអក្សរ

**ABC Dreaming** – Warren Brim. Magabala Books

**Animalia** – Graeme Base. Picture Puffins

**Dr Seuss’s ABC** – Dr Seuss. Random House

**I Spy, An Alphabet in Art** – Lucy Micklethwait. Greenwillow Book

សៀវភៅដែលដាក់ជាតារាងបញ្ជី អាចប្រើបាននៅទូទាំងអក្ខរកម្ម និងលេខនព្វន្តសម្រាប់គោលបំណងផ្សេងៗគ្នា។

**ចូលមើលវិបសៃថ៍របស់យើង ហើយស្វែងរកធនធានបន្ថែមទៀត ដើម្បីជួយកូនរបស់អ្នកឱ្យបានចាប់ផ្ដើមយ៉ាងល្អនៅសាលារៀន។**

education.nsw.gov.au/lit-and-num-at-home




# សៀវភៅភាសាអង់គ្លេសដើម្បីជួយរបស់កូនអ្នកអភិវឌ្ឍជំនាញលេខនព្វន្ត

## សៀវភៅអំពីលេខ និងការរាប់

**Counting on Community** – Innosanto Nagara. Seven Stories Press, Penguin.

**Counting with Tiny Cat** – Viviane Schwarz. Walker Books

**Five Little Ducks** – Penny Ives. Child's Play International Ltd

**One is a Snail, Ten is a Crab** – April Pulley Sayre and Jeff Sayre, illustrator Randy Cecil. Scholastic Australia

**One Woolly Wombat** – Kerry Argent. Scholastic Australia

**Ten Black Dots** – Donald Crews. Scholastic Australia

**Ten Little Dinosaurs** – Mike Brownlow, illustrator Simon Rickerty. Orchard Books

**Ten Little Jarjum** – Tabulam Aboriginal Community members, editors Suzi Williams and Kate Merrifield. NSW Board of Studies

**Ten Scared Fish** – Ros Moriarty, illustrator Balarinji. Allen and Unwin

## សៀវភៅអំពីការបូក និងការដក

**Five Little Monkeys Play Hide-and-seek** – Eileen Christelow. Houghton Mifflin

**Ten Little Beasties** – Rebecca and Ed Emberley. Macmillan

**Ten Little Fingers and Ten Little Toes** – Mem Fox, illustrator Helen Oxenbury. Puffin Books

**Ten Little Ladybugs** – Melanie Gerth, illustrator Laura Huliska-Beith. Intervisual Books Inc

**There Were 10 in the Bed** – illustrator Wendy Straw. Sweet Cherry Publishing

**The Shopping Basket** – John Burningham. Random House

**Uno's Garden** – Graeme Base. Penguin Books, Puffin

## សៀវភៅអំពីលំនាំ

**Anno's Counting Book** – Mitsumasa Anno. Harper Collins

**Caterpillar and Butterfly** – Ambelin Kwaymullina. Fremantle Press

**One fish, two fish, red fish, blue fish** – Dr Seuss. Random House

**The Very Hungry Caterpillar** – Eric Carle. Hamish Hamilton Press

© State of New South Wales (Department of Education), 2020.

The copyright material published in this resource is subject to the Copyright Act 1968 (Cth) and is owned by the NSW Department of Education or, where indicated, by a party other than the NSW Department of Education (third-party material).

Copyright material available in this resource and owned by the NSW Department of Education is licensed under a Creative Commons Attribution 4.0 International (CC BY 4.0) licence. This licence allows you to share and adapt the material for any purpose, even commercially.

Attribution should be given to © State of New South Wales (Department of Education), 2020.

Material in this resource not available under a Creative Commons licence:

- the NSW Department of Education logo, other logos and trademark-protected material
- material owned by a third party that has been reproduced with permission. You will need to obtain permission from the third party to reuse its material.

# សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរស័ព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 ហើយស្នើសុំអ្នកបកប្រែភាសា ជាភាសារបស់អ្នក។ សេវាកម្មនេះនឹងមិនគិតថ្លៃពីអ្នកទេ។

ក្រសួងអប់រំ រដ្ឋ NSW

NSW GOVERNMENT